CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច ៥៦២.៥៧០.NEWS (៦៣៩៧)
jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចផ្តល់ព័ត៌មានថ្មីៗអំពីកិច្ចប្រឹងប្រែងឆ្លើយតបនឹងការធ្វើបាតុកម្មប្រឆាំងតវ៉ា

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា – កាលពីម្សិលមិញនេះទីក្រុងឡុងប៊ិចបានមានការធ្វើបាតុកម្មនៅទូទាំងទីប្រជុំជន។ ដើម្បីធានាសុវត្ថិភាពនិងសុខុមាលភាពរបស់សហគមន៍មន្ទីរប៉ូលីសនិងមន្ទីរពន្លត់អគ្គីភ័យរួមជាមួយមន្ទីរក្រុងដទៃទៀតបានរៀបចំផែនការនិងត្រៀមសម្រាប់សកម្មភាពបាតុកម្មតវ៉ាដែលបានគ្រោងនឹងធ្វើនៅមុខទីបញ្ជាការប៉ូលីស។ ជាក់ស្តែងទីក្រុងបានប្រកាសអាសន្នហើយបានដាក់បំរាមគោចរនៅទូទាំងទីក្រុង។

មន្ទីរប៉ូលីសនៃទីក្រុងឡុងប៊ិចបានឃ្លាំមើលយ៉ាងដិតដល់នូវព្រឹត្តិការណ៍ផ្សេងៗនៅពេលដែលភាពចលាចលស៊ីវិលបានកើតឡើងនៅក្នុងសហគមន៍ដទៃទៀតនៅទូទាំងប្រទេស។ ទីក្រុងបានប្រមើលដោយប្រុងប្រយ័ត្នថាការធ្វើបាតុកម្មអាចនឹងកើតឡើងនៅឡុងប៊ិចផងដែរ។ ថ្នាក់ដឹកនាំនៃមន្ទីរប៉ូលីសបានបង្កើតផែនការសកម្មភាពមួយសម្រាប់ព្រឹត្តិការណ៍ដែលរួមមានការប្រាស្រ័យទាក់ទងជាមួយអាជីវកម្ម អង្គការ អ្នកដឹកនាំខាងជំនឿ និងកន្លែងនានាដែលនៅជុំវិញតំបន់ទីប្រជុំជន។ មុនពេលការធ្វើបាតុកម្មតវ៉ាដែលបានគ្រោងទុកបានចាប់ផ្តើមរបស់ណាដែលអាចប្រើជាអាវុធបានត្រូវដកចេញពីតំបន់ដែលបើកចំហនិងមន្ត្រីអនុវត្តច្បាប់បានលើកទឹកចិត្តឱ្យអាជីវកម្មធ្វើដូច្នេះផងដែ។ មន្ត្រីប៉ូលីសឡុងប៊ិច

រាប់រយនាក់ដែលលើសពីកំរិតបុគ្គលិកធម្មតាត្រូវបានកោះហៅឱ្យជួយ។ ផែនការបញ្ជូនចេញត្រូវបានបង្កើតឡើងដើម្បីធានាថានឹងមានបុគ្គលិកសម្រាប់ការឆ្លើយតបរយៈពេលជាច្រើនថ្ងៃ។

បេសកកម្មរបស់មន្ទីរប៉ូលីសគឺការពារនិងសម្រួលដល់សកម្មភាពដែលស្របតាមវិសោធនកម្មទីមួយ (First Amendment) នៃសហរដ្ឋអាមេរិកដែលប្រកបដោយសន្តិភាព។ ផែនការឆ្លើយតបក៏ត្រូវបានបង្កើតឡើងសម្រាប់ការប្រជុំមិនស្របច្បាប់និងសកម្មភាពខុសច្បាប់ដាច់ដោយឡែក។ ខណៈពេលដែលបុគ្គលភាគច្រើនបានបញ្ចេញសំលេងរបស់ពួកគាត់ដោយសន្តិវិធីគឺជាការអកុសលដែលមានបុគ្គលដែលបង្ហាញអាកប្បកិរិយាខុសច្បាប់ដោយការបំផ្លាញទ្រព្យសម្បត្តិនិងការលួចពីអាជីវកម្មជាច្រើនដែលមានទីតាំងនៅកណ្តាលទីក្រុង។

ទំហំនៃហ្វូងមនុស្សជាដំបូងត្រូវបានប៉ាន់ស្មានថាមានចំនួន 200 នាក់ហើយបានកើនដល់ 3,000 នាក់យ៉ាងឆាប់រហ័ស។ ដោយសារទំហំនៃហ្វូងមនុស្សបានបន្តកើនឡើងយ៉ាងឆាប់រហ័សប្រមាណមួយម៉ោងបន្ទាប់ពីការធ្វើបាតុកម្មដែលបានគ្រោងទុកបានចាប់ផ្តើមមន្ទីរប៉ូលីសបានផ្តួចផ្តើមនូវការស្នើសុំជំនួយជាច្រើនតាមរយៈក្រសួងប្រតិបត្តិការបន្ទាន់របស់មន្ទីរប៉ូលីសប្រចាំតំបន់ Los Angeles ដែលជាដំណើរការក្នុងតំបន់ក្នុងការស្នើសុំជំនួយ។ ទូទាំងព្រឹត្តិការណ៍នេះមន្ត្រីជាង ១០០ នាក់មកពីទីភ្នាក់ងារដូចខាងក្រោមត្រូវបានប្តូរទីតាំងមលទីក្រុងឡុងប៊ិចដោយផ្អែកលើការស្នើសុំជំនួយៈ មន្ទីរប៉ូលីស Los Angeles មន្ទីរតំរួតនៃតំបន់ Ventura County ប៉ូលីសកំពង់ផែ Los Angeles ប៉ូលីសនៃទីក្រុង Seal Beach ប៉ូលីសនៃទីក្រុង Signal Hill និងក្រុមជំនួយរួមនៃតំបន់ Area G (ទីក្រុងឆកសមុទ្រខាងត្បូងនិង Inglewood)។ តាមដំណើរការរបស់រដ្ឋនិងខោនធីសម្រាប់ការស្នើសុំជំនួយនៅពេលដែលធនធានជំនួយទាំងអស់ត្រូវបានអស់ដោយសារព្រឹត្តិការណ៍ផ្សេងទៀតនៅក្នុងតំបន់ខោនធីនិងរដ្ឋបានយល់ព្រមឱ្យឆ្មាំជាតិមកជួយនៅឡុងប៊ិច។

បុគ្គលជាច្រើនត្រូវបានចាប់ខ្លួននិងចោទពីបទផ្សេងៗរួមមានការលួចប្លន់និងការរំលោភបម្រាមគោចរ។ អាជីវកម្មនៅតាមទីប្រជុំជនជាច្រើនត្រូវបានគេលួចនិងបំផ្លាញហើយរថយន្តប៉ូលីសជាច្រើនត្រូវបានខូចខាត។ ចាប់ពីល្ងាចនេះតទៅមន្ទីរប៉ូលីសនឹងបន្តវាយតម្លៃនិងចងក្រងឯកសារទាក់ទងនឹងផលប៉ះពាល់ដែលជាលទ្ធផលនៃព្រឹត្តិការណ៍។ ស្ថិតិបន្ថែមនឹងត្រូវផ្តល់ជូននៅថ្ងៃនេះ។

ពេញមួយល្ងាចមន្ទីរពន្លត់អគ្គីភ័យនៅឡុងប៊ិចបានឆ្លើយតបទៅនឹងសំណូមជាច្រើនសម្រាប់សេវាកម្ម។ ឧប្បត្តិហេតុទាំងនេះរួមមានទាំងជំនួយវេជ្ជសាស្ត្រនិងការឆ្លើយតបនឹងអគ្គីភ័យ។ សមាជិកសហគមន៍និងបុគ្គលិកទីក្រុងមិនបានរាយការណ៍អំពីការរងរបួសធ្ងន់ធ្ងរទេ។ ធនធានអគ្គីភ័យពីយុត្តាធិការជិតខាងក៏ត្រូវបានស្នើសុំតាមរយៈប្រព័ន្ធជំនួយទៅវិញទៅមក។ នេះរារាំងការរីកយ៉ាងឆាប់រហ័សនៃអគ្គីភ័យតូចៗដែលអាចនាំឱ្យមានការបាត់បង់កាន់តែច្រើននៅក្នុងទីក្រុងរបស់យើង។ ក្នុងចំណោមអគ្គីភ័យដែលបានរាយការណ៍មានតែឧប្បត្តិហេតុមួយទេដែលបានកើនឡើងដល់កម្រិតនៃភាពធ្ងន់ធ្ងរដែលត្រូវការធនធានជាច្រើននិងការវាយប្រហារចំពោះភ្លើងឆេះរយៈពេលយូរ។ អគ្គីភ័យនេះបានកើតឡើងនៅហាងលក់សម្លៀកបំពាក់មួយនៅលើ 600 block នៃផ្លូវ Pine Avenue។

មន្ទីរសាធារណការនៅតែបន្តជួយក្នុងការដាក់ក្តារជាបន្ទាន់និងការដករូបគំនូរនិងការសរសេរលើជញ្ជាំងសាធារណៈហើយក្រុមសម្អាតនឹងជួយសហគមន៍នៅពេលទីក្រុងផ្លាស់ប្តូរទៅរកការស្តារឡើងវិញ។ អ្នកស្ម័គ្រចិត្តនឹងទៅតំបន់ទីប្រជុំជននៅថ្ងៃនេះដើម្បីជួយដល់ក្រុមសម្អាតរបស់ក្រុងហើយយើងសូមអរគុណពួកគាត់ចំពោះជំនួយនេះ។ ទោះបីជានៅពេលបច្ចុប្បន្នមិនមានបាតុកម្មដែលបានគ្រោងទុកនៅថ្ងៃនេះទីក្រុងនឹងបន្តរៀបចំហើយនឹងឆ្លើយតបទៅនឹងប្រភេទនៃឧប្បត្តិហេតុសំខាន់ៗ ការប្រមូលផ្តុំ ឬភាពចលាចលស៊ីវិល។ បំរាមគោចរសម្រាប់យប់នេះត្រូវបានគ្រោងទុកហើយព័ត៌មានលម្អិតបន្ថែមនឹងត្រូវប្រកាសនាពេលក្រោយនៅថ្ងៃនេះ។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេង

ហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័
រ Instagram និង យូធ្យូប។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័សង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #